# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## វិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងសន្តិសុខអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះកំណត់អំពីវិធានការនានាទាក់ទងនឹងការធ្វើចត្តាឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងបញ្ចៀសឱ្យបានជាអតិបរមានូវផលប៉ះពាល់ដល់ផ្នែកសង្គម និងសេដ្ឋកិច្ច។

**មាត្រា២ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការធ្វើចត្តាឡីស័កនៅតាមច្រកចេញចូល និងក្នុងផ្ទៃប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៣ ..**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការចាត់វិធានការចត្តាឡីស័ក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីចាំបាច់ ក្រសួងសុខាភិបាលត្រូវសហការជាមួយនឹងក្រសួងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការអន្តរជាតិដែលមានការពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការចត្តាឡីស័កឱ្យមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី៣
## វិធានការចត្តាឡីស័ក

**មាត្រា៤ ..**

ការធ្វើចត្តាឡីស័ក ត្រូវអនុវត្តចំពោះរាល់ពលរដ្ឋខ្មែរ និងជនបរទេស ដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាតាមគ្រប់មធ្យោបាយ និងបុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬជាមួយអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩។

សម្រាប់ពលរដ្ឋខ្មែរ និងជនបរទេសដែលធ្វើដំណើរពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ការធ្វើចត្តាឡីស័កត្រូវធ្វើនៅក្នុងមណ្ឌលចត្តាឡីស័កណាមួយដែលកំណត់ដោយក្រសួងសុខាភិបាល ឬទីកន្លែងណាមួយផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខាភិបាល ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច។

សម្រាប់បុគ្គលដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬជាមួយអ្នកដែលសង្ស័យថាមានផ្ទុកមេរោគកូវីដ-១៩ ការធ្វើចត្តាឡីស័កអាចធ្វើនៅមណ្ឌលចត្តាឡីស័កណាមួយ ឬនៅលំនៅឋានផ្ទាល់ខ្លួនរបស់បុគ្គលនោះ ឬទីកន្លែងណាមួយផ្សេងទៀត តាមការកំណត់របស់ក្រសួងសុខាភិបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច ដោយផ្អែកលើស្ថានភាពបុគ្គល ស្ថានភាពគ្រួសារ និងស្ថានភាពលំនៅឋានរបស់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កនោះ។

**មាត្រា៥ ..**

រយៈពេលនៃការធ្វើចត្តាឡីស័ក ត្រូវកំណត់ដោយក្រសួងសុខាភិបាល។

**មាត្រា៦ ..**

ក្នុងការធ្វើចត្តាឡីស័ក បុគ្គលដែលធ្វើចត្តាឡីស័ក ត្រូវអនុវត្តកាតព្វកិច្ច ដូចខាងក្រោម៖

១- អនុវត្តឱ្យបានត្រឹមត្រូវតាមវិធានការសុខាភិបាលដែលកំណត់ដោយក្រសួងសុខាភិបាល

២- មិនត្រូវចាកចេញពីទីកន្លែងធ្វើចត្តាឡីស័ក ដោយគ្មានការអនុញ្ញាតពីមន្ត្រីចត្តាឡីស័ក

៣- សហការជាមួយមន្ត្រីសុខាភិបាលដើម្បីធ្វើការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩

៤- សហការក្នុងការផ្ដល់ព័ត៌មានដល់មន្ត្រីសុខាភិបាល អំពីបុគ្គលដែលសង្ស័យថាអាចមានជំងឺកូវីដ-១៩ ឬអ្នកដែលបានប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកជំងឺកូវីដ-១៩ ឬអ្នកដែលត្រូវធ្វើចត្តាឡីស័ក និងផ្ដល់ព័ត៌មានផ្សេងទៀតតាមការចាំបាច់។

បែបបទ និងនីតិវិធីសម្រាប់ការធ្វើចត្តាឡីស័ក ត្រូវកំណត់ដោយក្រសួងសុខាភិបាល។

## ជំពូកទី៤
## កម្រៃទាក់ទងនឹងការធ្វើចត្តាឡីស័ក

**មាត្រា៧ .-**

កម្រៃនានាក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា៨ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលគេចវេះពីការធ្វើចត្តាឡីស័កតាមការកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។

**មាត្រា៩ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ដូចមានចែងក្នុងមាត្រា៦ ចំណុច ២ នៃអនុក្រឹត្យនេះ។

**មាត្រា១០ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ចំពោះបុគ្គលដែលធ្វើចត្តាឡីស័ក ដែលមិនសហការជាមួយមន្ត្រីសុខាភិបាល ដើម្បីយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ដូចមានចែងក្នុងមាត្រា៦ ចំណុច ៣ នៃអនុក្រឹត្យនេះ។ ការបង់ប្រាក់ពិន័យអន្តរការណ៍នេះ មិនធ្វើឱ្យបុគ្គលដែលត្រូវធ្វើចត្តាឡីស័ករួចផុតពីកាតព្វកិច្ចក្នុងការឱ្យមន្ត្រីសុខាភិបាលយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ នោះទេ។

**មាត្រា១១ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះអ្នកផ្ដើមគំនិត ដឹកនាំ ណែនាំ ញុះញង់ បញ្ចុះបញ្ចូល ឬជួយសម្រួលដោយចេតនា ដល់បុគ្គលដែលត្រូវធ្វើចត្តាឡីស័កឱ្យគេចចេញពីការត្រួតពិនិត្យរបស់មន្ត្រីចត្តាឡីស័ក ឬគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីកន្លែងធ្វើចត្តាឡីស័ក។

**មាត្រា១២ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះគ្រឹះស្ថានសុខាភិបាលឯកជនទាំងអស់ ដែលជួយលាក់បាំង និងមិនបានធ្វើការជូនដំណឹងបន្ទាន់ទៅក្រសួងសុខាភិបាល ក្នុងករណីពិនិត្យឃើញថា អ្នកជំងឺដែលកំពុងទទួលសេវាព្យាបាលនៅក្នុងគ្រឹះស្ថានរបស់ខ្លួនមានតម្រុយបញ្ជាក់ថាជាអ្នកជំងឺដែលគេចវេះពីការធ្វើចត្តាឡីស័ក ឬកំពុងគេចចេញពីកន្លែងធ្វើចត្តាឡីស័ក។

**មាត្រា១៣ .-**

ប្រាក់ពិន័យអន្តរការណ៍ដែលបានកំណត់ពីមាត្រា៨ ដល់មាត្រា១២ នៃអនុក្រឹត្យនេះ ត្រូវកើនឡើងទ្វេដង ក្នុងករណីដែលអំពើល្មើសត្រូវបានប្រព្រឹត្តម្ដងទៀត។

**មាត្រា១៤ .-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ។ នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។ ក្នុងករណីនេះ មន្ត្រីសុខាភិបាលដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

**មាត្រា១៥ .-**

ការបង់ប្រាក់ពិន័យអន្តរការណ៍ដូចមានចែងក្នុងជំពូកទី៥ នៃអនុក្រឹត្យនេះ មិនធ្វើឱ្យបុគ្គលដែលត្រូវធ្វើចត្តាឡីស័ក រួចផុតពីកាតព្វកិច្ចក្នុងការធ្វើចត្តាឡីស័កឡើយ។

**មាត្រា១៦ .-**

ក្នុងករណីបុគ្គលដែលបានប្រព្រឹត្តល្មើសដូចមានចែងពីមាត្រា៨ ដល់មាត្រា១២ នៃអនុក្រឹត្យនេះ មិនបានបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្ដីសម្រេចស្ដីពីការពិន័យអន្តរការណ៍ មន្ត្រីសុខាភិបាលដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

**មាត្រា១៧ .-**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពាន ខុសពីគោលបំណងនៃអនុក្រឹត្យនេះ ហើយបង្កការប៉ះពាល់ដល់រូបរាងកាយ ឬការខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៨ .-**

ការពិន័យអន្តរការណ៍ដែលមានចែងក្នុងអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៩ .-**

ការអនុវត្តបទប្បញ្ញត្តិជំពូកទី៥ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើបំពានលើបទប្បញ្ញត្តិដែលចែងក្នុងអនុក្រឹត្យនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា២០ .-**

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៨ មាត្រា៩ និងមាត្រា១១ នៃអនុក្រឹត្យនេះ នឹងអាចត្រូវលើកលែងឱ្យរួចផុតពីការទទួលពិន័យអន្តរការណ៍ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់ មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្ដល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ការលើកលែងឱ្យរួចផុតពីការទទួលពិន័យអន្តរការណ៍នេះ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលត្រូវធ្វើចត្តាឡីស័កហើយដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា៨ មាត្រា៩ និងមាត្រា១១ នៃអនុក្រឹត្យនេះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាល ឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២១ .-**

បទដ្ឋានគតិយុត្តទាំងឡាយណាដែលមានមុនអនុក្រឹត្យនេះ ត្រូវបន្តមានអានុភាពអនុវត្តហូតដល់មានបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ៣.រោចកើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ម៉ម ប៊ុនហេង** **កើត រិទ្ធ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ